- ទទួលបានសៀវភៅសិក្សាសំរាប់ម៉ូឌុលនិមួយៗដើម្បីគាំទ្រដល់ការងារប្រចាំថ្ងៃ។ (ឯកសារនឹងចែកជូនជា ភាសាខ្មែរ អង់គ្លេស និងចិន)។
- រោងចក្រទទួលការគាំទ្រពីក្រុមការងារកែលំអរោងចក្រកាត់ដេរដើម្បីជួយក្នុងការអនុវត្តការកែលំអ។
- ទទួលបានឯកសារនៃការអនុវត្តល្អមដោយរូបភាពដែលឆ្លុះបញ្ចាំងគំនិតល្អៗពីរោងចក្រដ៏ទៃទៀតនៅក្នុងប្រទេសកម្ពុជាដែលបង្ហាញពីរបៀបកែលំអផលិតភាព គុណភាព និងលក្ខខណ្ឌការងារ។
- ទទួលបានឱកាសចូលរួមក្នុងបណ្តាញការងារជាមួយនឹងរោងចក្រដ៏ទៃៗទៀតដែលចូលរួមក្នុងកម្មវិធី។



## ពត៌មានស្តីពីសិក្ខាសាលា

អង្គការពលកម្មអន្តរជាតិ និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជានឹងរៀបចំសិក្ខាសាលានៅថ្ងៃទី ០៤ ខែតុលាឆ្នាំ ២០០៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា ចាប់ពីម៉ោង ០៨:៣០ ព្រឹក ដល់ ម៉ោង ១២:៣០ ល្ងាច ដើម្បីផ្លាស់ប្តូរបទពិសោធន៍ពីរោងចក្រ ដែលបានចូលរួមក្នុងកម្មវិធីសាកល្បងពីមុនមក និងផ្តល់ពត៌មានលំអិតបន្ថែមស្តីពីកម្មវិធី។

## អ្នកផ្តល់ការបណ្តុះបណ្តាល

ការបណ្តុះបណ្តាលនឹងដឹកនាំដោយមានកិច្ចសហការណ៍ជាមួយនឹងវិទ្យាស្ថាន VBNK ដែលជាវិទ្យាស្ថាននាំមុខគេក្នុងការបណ្តុះបណ្តាល និងបានបង្កើតកិត្តិសព្ទ័សំរាប់អាជីពនៃការផ្តល់ការបណ្តុះបណ្តាលដ៏មានគុណភាព។

## ថ្លៃចំណាយ

រោងចក្រដែលចូលរួមនឹងត្រូវបង់ថ្លៃជាមុនសំរាប់ការបណ្តុះបណ្តាលចំនួន ១៧៥០ដុល្លាអាមេរិក។ ការបង់ថ្លៃនេះគឺសំរាប់វគ្គបណ្តុះបណ្តាលទាំងមូល ឯកសារបណ្តុះបណ្តាល និងការចុះជួយគាំទ្រដល់រោងចក្រលើការងារដែលពាក់ព័ន្ធទៅនឹងកម្មវិធី។ ការបង់ថ្លៃនេះគឺជាការជួយរំលែកភាគខ្លះនៃការចំណាយប៉ុណ្ណោះ ដោយគំរោងកែលំអលក្ខខណ្ឌការងារនៃអង្គការពលកម្មអន្តរជាតិជាអ្នករ៉ាប់រងលើចំណាយដ៏ទៃៗទៀត។

### ពត៌មានបន្ថែម

សូមដាក់ពាក្យសុំចូលក្នុងកម្មវិធី ដោយបំពេញទម្រង់បែបបទភ្ជាប់មកជាមួយស្រាប់ ហើយផ្ញើតាមរយះ អ៊ីម៉ែលphearun@ilogsp.org.kh ឬហ្វាក់លេខ ០២៣ ២១២ ៩០៣ មកឈ្មោះលោក វ៉ា ភារុន ឱ្យទាន់ថ្ងៃទី ២១ តុលា ២០០៤។ បើលោក លោកស្រីចង់ដឹងពត៌មានបន្ថែមស្តីពីកម្មវិធី សូមទាក់ទងអ្នកស្រី ម៉ូធីតា ជិន អ្នកជំនួយការប្រធានកម្មវិធីកែលំអរោងចក្រកាត់ដេរ តាមរយះទូរស័ព្ទលេខ ០២៣ ២១២ ៨៤៧ លេខបន្ត ១១៤ ឬតាមរយះអ៊ីម៉ែល motthida@ilogsp.org.kh ។


INTERNATIONAL LABOUR ORGANISATION
Garment Sector Working Conditions Improvement Project-Remediation Program

N° 9, St. 322
Boeung Keng Kang I
Chamcamon, Phnom Penh
Cambodia, P.O Box: 2642
Tel: (855-23) 220 362
Fax: (855-23) 212 903
E-mail: gsp@ilogsp.org.kh

An Institute for Managers of Organisations Working for the Development of Cambodia

N° 28 St. 80 (Corner Street 75)
Srass Chak, Khann Daun Penh
Phnom Penh
Cambodia, P.O Box: 2307
Tel: (855-23) 722 115
Fax: (855-23) 722 117
E-mail: office@vbnk.org
Website: www.vbnk.org


# កម្មវិធីបណ្តុះបណ្តាល រោងចក្រឱ្យកាន់តែប្រសើរឡើង

ILO - គំរោងវិស័យកាត់ដេរ



## ទិដ្ឋភាពទូទៅ

ឧស្សាហកម្មកាត់ដេរ គឺជាអ្នករកប្រាក់ចំណូលលើការនាំចេញឈានមុខគេរបស់ប្រទេសកម្ពុជា។ ឧស្សាហកម្មនេះនឹងជួបប្រទះការប្រកួតប្រជែងកាន់តែខ្លាំងឡើងនៅពេលដែលប្រទេសកម្ពុជាក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក(WTO) និង ប្រព័ន្ធកូតាត្រូវបានបញ្ចប់។

ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីទាញយកផលចំណេញពីឱកាសទីផ្សារដែលកំពុងតែរីកធំឡើង គំរោងវិស័យកាត់ដេររបស់អង្គការពលកម្មអន្តរជាតិILO និងវិទ្យាស្ថានបណ្តុះបណ្តាល VBNK រួមសហការជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) នឹងរៀបចំកម្មវិធីបណ្តុះបណ្តាលក្នុងគោលបំណងជួយឧស្សាហកម្មកាត់ដេររបស់ប្រទេសកម្ពុជាអោយរៀបចំខ្លួនដើម្បីប្រឈមមុខយកឈ្នះនឹងបញ្ហានៅពេលខាងមុខ។



## ការបណ្តុះបណ្តាល

នៅឆ្នាំ ២០០៣ និង ២០០៤ អង្គការ ILO បានអនុវត្តកម្មវិធីបណ្តុះបណ្តាលសាកល្បងដែលមានរោងចក្រ ៧ បានចូលរួម។ កម្មវិធីសាកល្បងនេះបានទទួលជោគជ័យដ៏ត្រចះត្រចង់។ រោងចក្រដែលបានចូលរួមបានបង្ហាញពីការរីកចំរើនដែលអាចវាស់បានក្នុងផ្នែកផលិតភាព ប្រសិទ្ធភាព និងលក្ខខណ្ឌការងារ។ ឥឡូវនេះកម្មវិធីបណ្តុះបណ្តាលសំរាប់វគ្គទីពីរដែលមានបញ្ចូលប្រធានបទថ្មីៗ និងឯកសារដែលទាក់ទងផ្ទាល់ដល់ប្រទេសកម្ពុជាកំពុងត្រូវបានរៀបចំឡើង។ រោងចក្រចំនួន ១៤ នឹងត្រូវបានផ្តល់ឱកាសអោយចូលរួមក្នុងវគ្គទីពីរនេះ។ ដើម្បីអោយការបណ្តុះបណ្តាលទទួលបានលទ្ធផលជាអតិបរិមា កម្មវិធីបណ្តុះបណ្តាលនេះនឹងកំណត់យកតែសិក្ខាកាម ចំនួន២៨នាក់ប៉ុណ្ណោះក្នុងសិក្ខាសាលានិមួយៗ។ ក្នុងនោះរោងចក្រមួយអាចបញ្ជូនតំណាងនិយោជក ២នាក់ និង តំណាងកម្មករ ២នាក់។ គ្រប់សិក្ខាសាលាទាំងអស់នឹងមានការបកប្រែប្រដេញពីភាសា អង់គ្លេសទៅ ខ្មែរ និងចិន ហើយពីភាសាខ្មែរ និងចិន ទៅអង់គ្លេស។ គ្រប់ឯកសារបណ្តុះបណ្តាល ទាំងអស់នឹងមានជា ៣ភាសា គឺ ភាសាខ្មែរ ចិន និង អង់គ្លេស។



## វិធីសាស្ត្របណ្តុះបណ្តាល

ការចាប់អារម្មណ៍កាន់តែច្រើនឡើងចំពោះលក្ខខណ្ឌការងារ រួមនិងបរិយាកាសប្រកួតប្រជែងលើឆាកអន្តរជាតិ នាំអោយមានតំរូវការផ្តល់ការបណ្តុះបណ្តាលប្រកបដោយគុណភាពដើម្បីអោយសិក្ខាកាមមានសមត្ថភាពរកឃើញបញ្ហាកង្វល់ និងស្វែងរកដំណោះស្រាយដែលងាយស្រួលអនុវត្ត។ ការបណ្តុះបណ្តាលនេះនឹងប្រើប្រាស់វិធីសាស្ត្រចូលរួមពិភាក្សាដើម្បីអោយសិក្ខាកាមនិមួយៗមានឱកាសចែករំលែកទស្សនៈរបស់គេម្នាក់ៗ ក៏ដូចជាកសាងបទពិសោធន៍របស់គេបន្ថែមទៀត។ សិក្ខាសាលារយៈពេល ២ថ្ងៃ រួមមានការធ្វើកម្មវិធីកែលំអដោយខ្លួនឯងដែលក្នុងកម្មវិធីនេះសិក្ខាកាមនឹងវិលត្រលប់ទៅកន្លែងធ្វើការរបស់ខ្លួនវិញដើម្បីអនុវត្តនូវអ្វីដែលខ្លួនបានរៀនពីសិក្ខាសាលា។ វគ្គសិក្សានឹងត្រូវរៀបរៀងដោយអ្នកឯកទេសអន្តរជាតិ និងតំណាងអ្នកទិញធំៗមួយចំនួនដើម្បីធានាអោយបានថាការបណ្តុះបណ្តាល និងការអនុវត្តមានភាពទាក់ទងគ្នា។



## មាតិកា

វគ្គបណ្តុះបណ្តាលថ្មីនេះចែកចេញជា ៧ ម៉ូឌុល ហើយមានរយះពេល ១២ ខែ។ ក្នុងចន្លោះពីម៉ូឌុលមួយទៅម៉ូឌុលមួយទៀត រោងចក្រនិមួយៗនឹងទទួលបានការជួយជ្រោមជ្រែងពីផ្នែកកែលំអរោងចក្រកាត់ដេររបស់អង្គការ ILO ដើម្បីអនុវត្តនូវអ្វីដែលខ្លួនបានរៀន។

ម៉ូឌុលទាំង ៧ រួមមាន:

- បរិបទនៅជុំវិញសកលលោក
- កិច្ចសហប្រត្តិបត្តិការនៅកន្លែងការងារ
- គុណភាព
- សុខភាព និង សុវត្ថិភាពការងារ
- ផលិតភាព
- ការគ្រប់គ្រងធនធានមនុស្ស និង លក្ខខណ្ឌការងារ
- ការកែលំអជាប្រចាំ

## រោងចក្រដែលនឹងចូលរួមមានសិទ្ធិទទួលបានផលប្រយោជន៍ដូចតទៅ:

- ការវិភាគពីតំរូវការក្នុងរោងចក្រនិមួយៗដើម្បីរៀបចំអាទិភាពសំរាប់ម៉ូឌុលនិមួយៗ។
- រៀបចំអាំងឌីការទ័រអនុវត្តសំខាន់ៗ ដើម្បីឱ្យមានភាពងាយស្រួលសំរាប់វាស់វែងការរីកចំរើន។
- ចូលរួមសិក្ខាសាលា និងការបណ្តុះបណ្តាលតំរូវតាមរោងចក្រដែលនឹងធ្វើឡើងដោយអ្នកឯកទេសអន្តរជាតិ និង ជាតិផងដែរ។